ការប្រកួតសំណេរ ២០១៨

ថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩

# ប្រធានបទ៖ តើទិសដៅវិស័យអប់រំកម្ពុជាឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍ២០៣០ ឬទេ?

ប៉ាវី សុភារ័ត្ន*
ជ័យលាភីលេខ ១ របស់ការប្រកួតសំណេរឆ្នាំ ២០១៨

**សេចក្តីសង្ខេប (Executive Summary)**

The Royal Government of Cambodia desires to lift Cambodia out of poverty, become a higher-middle-income country by 2030. Human resource development and vocational training are the major mechanisms needed to realize this strategy. The Ministry of Education, Youth and Sports ( MoEYS ) has begun education reform since 2014, setting out a strategic plan 2014-2018 regarding the government's 2030 vision, "to develop human resources of the very high quality and ethics in order to develop a knowledge-based society within Cambodia". I believe that Cambodian Education is on the right track. However, there are some suggestions regarding Public-Private-Partnership, Technology Investment and Education Culture-Religious Cooperation to better improve the implementation of the strategy.

## I. គោលដៅអភិវឌ្ឍ២០៣០ និងទិសដៅវិស័យអប់រំនៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញអំពីក្តីបំណងក្នុងការនាំយកប្រទេសកម្ពុជា ឱ្យឆ្លងផុតពីភាពក្រីក្រ ផ្លាស់ប្តូរមុខមាត់ថ្មី ដើម្បីក្លាយជាប្រទេស ដែលមានចំនូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០ ហើយក្លាយជាប្រទេសអភិវឌ្ឍដែលមានចំនូលខ្ពស់ត្រឹមឆ្នាំ២០៥០ នេះបើយោងតាមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ និងដំណាក់កាលទី៤ ដែលទើបបានដាក់ចេញជាសាធារណៈក្នុងពេលកន្លងមកនេះ។ ក្រសួងពាក់ព័ន្ធនានា ក្នុងប្រទេសកម្ពុជា បានដាក់ចេញគោលនយោបាយរបស់ខ្លួនផ្សេងៗគ្នា ដោយបង្ហាញពីយុទ្ធសាស្រ្ត ក៏ដូចជាទស្សនវិស័យរបស់ស្ថាប័នខ្លួន ធ្វើយ៉ាងណាជម្រុញ និងឆ្លើយតបទៅនឹងយុទ្ធសាស្រ្តគោល និងកម្មវិធីនយោបាយជាតិ។

ការកសាងធនធានមនុស្ស និងការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ គឺជាយន្តការសំខាន់ចម្បងទី១ក្នុងយុទ្ធសាស្រ្តចតុកោណទាំង២ដំណាក់កាលចុងក្រោយ (ទី៣ និងទី៤)ផងដែរ។ វិស័យអប់រំត្រូវបានចាត់ទុកថាជាវិស័យដ៏ចម្បងមួយដែលអាចជួយត្រួសត្រាយផ្លូវសម្រាប់កម្ពុជា ដើម្បីឆ្ពោះទៅកាន់គោលដៅឆ្នាំ ២០៣០ របស់ខ្លួន។ ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមកំណែ

*ប៉ាវី សុភារ័ត្ន គឺជានិស្សិតដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

© រក្សាសិទ្ធិដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

ទម្រង់វិស័យអប់រំ តាំងពីឆ្នាំ២០១៤ ដោយបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ២០១៤-២០១៨ ទាក់ទងនឹងចក្ខុវិស័យ ២០៣០ របស់រដ្ឋាភិបាល គឺធ្វើយ៉ាងណា "កសាងសេដ្ឋកិច្ច ឱ្យមានការប្រកួតប្រជែង សុខដុមនីយកម្ម និងនិរន្តរភាព"។ ផែនការយុទ្ធសាស្ត្រនេះ បានបង្ហាញផងដែរពីចក្ខុវិស័យរបស់ក្រសួងអប់រំ ដោយផ្តោតទៅលើ "ទិសដៅវិស័យអប់រំធ្វើយ៉ាងណា កសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះដឹងធ្វើជាមូលដ្ឋាន"។ ក្រសួងអប់រំបានបង្ហាញអំពីគោលនយោបាយអប់រំសំខាន់ចំនួន៣ ដើម្បីជាពុម្ពគម្រូមួយអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាឆ្លើយតប ទៅនឹងគោលដៅអភិវឌ្ឍន៏ឆ្នាំ២០៣០។

គោលនយោបាយនេះមានដូចជា៖

១. ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌

២. លើកកម្ពស់គុណភាព និងភាពឆ្លើយតប

៣. ធានាស័ក្តិសិទ្ធភាពនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់ជាន់ថ្នាក់។

ក្រសួងបានផ្តោតលើអនុវិស័យ៧ចម្បងគឺ ការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំមធ្យមសិក្សា និងការអប់រំបច្ចេកទេស ការអប់រំឧត្តមសិក្សា ការអប់រំក្រៅប្រព័ន្ធ ការអភិវឌ្ឍយុវជន និងកាយរឹទ្ធ និងកីឡា។ គោលនយោបាយទាំងនេះ ជម្រុញឱ្យក្រសួងអប់រំសម្រេចបាន នូវចក្ខុវិស័យរបស់ខ្លួន ការផ្តល់សេវាអប់រំត្រូវប្រកបដោយសមធម៌ តម្លាភាព វិជ្ជាជីវៈ និងគណនេយ្យភាពជាមូលដ្ឋាន ផ្តល់សេវាឱ្យមានគុណភាពតាមស្តង់ដាឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ យុវជន សហគមន៍ និងទីផ្សារការងារ។ នេះជាការរៀបរាប់ត្រួសៗពាក់ព័ន្ធនឹង ផែនការយុទ្ធសាស្ត្រ២០១៤-២០១៨ ។

បើយើងក្រលេកមើលសកម្មភាពផ្សេងៗដែលក្រសួងអប់រំបានអនុវត្ត និងកំពុងអនុវត្តចាប់ពីឆ្នាំ២០១៤ ដល់បច្ចុប្បន្ន (២០១៨) ឃើញថាមានការផ្លាស់ប្តូរជាវិជ្ជមានភាគច្រើន ចាប់ផ្តើមពីការលុបបំបាត់បញ្ហាអំពើពុករលួយ និងការលួចចម្លងអំឡុងពេលប្រលងមធ្យមសិក្សាទុតិយភូមិ ការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យអប់រំដូចជាការបង្កើតកម្មវិធីក្នុងទូរស័ព្ទ ឬវីដេអូបង្រៀននានា ការបង្កើតកម្មវិធីទាក់ទងនឹងវិទ្យាសាស្ត្រ រហូតដល់ការបង្កើតសាលារៀនជំនាន់ថ្មីទៀតផង។ ក្នុងនោះផងដែរ រាប់បញ្ចូលទាំងការដាក់ចេញគោលនយោបាយដទៃទៀតជាច្រើន ដើម្បីសម្រួលដល់ ការសម្រេចនយោបាយវិស័យអប់រំ មានដូចជា "គោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការក្នុងវិស័យអប់រំ" "ផែនការធនធានមនុស្សស្តីពីវិស័យអប់រំ" "ផែនការគោលសម្រាប់ការអប់រំបច្ចេកទេស នៅមធ្យមសិក្សាទុតិយភូមិ" "គោលនយោបាយស្តីពី ចក្ខុវិស័យឧត្តមសិក្សា២០៣០" និងគោលនយោបាយជាច្រើនផ្សេងទៀត។ ក្រៅពីនេះ ក្រសួងអប់រំ បានចាប់ដៃគូសហការ ជាមួយអង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការទាក់ទងនឹងវិស័យអប់រំ ដើម្បីជម្រុញបន្ថែមលើបច្ចេកវិទ្យាថ្មី និងការផ្សព្វផ្សាយនានាដូចជា ការអប់រំស្តីពីការណែនាំការជ្រើសរើសជំនាញថ្នាក់ឧត្តមសិក្សា ការយល់ដឹងពីមុខរបរស្របនឹងទីផ្សារ ការបញ្ជ្រៀបការយល់ដឹងពីសារប្រយោជន៍នៃមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា (ស្ទែម STEM) ជាដើម។

## II. តើទិសដៅនេះឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៏២០៣០ ដែរឬទេ?

ការដាក់ចេញនូវ គោលនយោបាយច្បាស់លាស់ ការអនុវត្តប្រកបដោយគណនេយ្យភាព គួបផ្សំនឹងការអប់រំផ្សព្វផ្សាយ ខ្ញុំយល់ថាទិសដៅអប់រំរបស់កម្ពុជាស្ថិតនៅលើគន្លងមួយដែលត្រឹមត្រូវ ក៏ប៉ុន្តែត្រូវបន្ថែមល្បឿនទៅមុខឱ្យបានប្រសើរជាងនេះ។ ឧទាហរណ៍ពីតថភាពជាក់ស្តែង ដោយសារតែខ្ញុំជាបេក្ខភាព ប្រលងមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៤ ដែលជាឆ្នាំកែទម្រង់ប្រព័ន្ធអប់រំដំបូង អាចនិយាយបានថាជាកណ្តុរពិសោធន៍ម្នាក់ ក្នុងផែនការយុទ្ធសាស្ត្រ ២០១៤-២០១៨ ខ្ញុំយល់ថាទិសដៅអភិវឌ្ឍន៏ដែលបានដាក់ចេញដោយក្រសួងអប់រំ សម្រាប់ខ្ញុំកំពុងតែមានផ្លែផ្កាជាបណ្តើៗហើយ

ដោយសារខ្ញុំខ្លួនឯងដែលកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាប័ត្រឆ្នាំទី៤ បានក្លាយជាផ្នែកមួយនៃក្រុមមនុស្សសកម្មដែលអាចរកប្រាក់ចំនូល ដោយប្រើប្រាស់ចំណេះដឹងរបស់ខ្លួន ប៉ុន្តែការទទួលបានការងាររបស់ខ្ញុំ ក៏ជាលទ្ធផលគួបផ្សំនឹងការអនុវត្ត បន្ទាប់ពីការសិក្សានៅក្នុងថ្នាក់ ដោយមិនផ្អែកលើការរៀនទ្រឹស្តីពីសាលាតែមួយមុខនោះទេ។ គួររំលឹកផងដែរថា "ទិសដៅវិស័យអប់រំធ្វើយ៉ាងណា កសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន"។

*តើទិសដៅនេះអាចដឹកដៃប្រជាជនកម្ពុជារាប់លាននាក់ផ្សេងទៀត ឬនាំប្រទេសកម្ពុជាទាំងមូល ឱ្យក្លាយជាប្រទេសដែលមានចំនូលមធ្យមកម្រិតខ្ពស់ ដែរឬទេ? ចម្លើយគឺ ជោគជ័យដោយអាស្រ័យ! ដោយសារហេតុថាទិសដៅអប់រំ មិនគួរដាក់បន្ទុកតែលើក្រសួងអប់រំតែមួយផ្នែកនោះទេ តែត្រូវមានការចូលរួម និងការសម្រប សម្រួលពីគ្រប់ភាគីពាក់ព័ន្ធ រួមនឹងឯកជនផងដែរ។*

យោងតាមធនាគារពិភពលោក (គ្មានថ្ងៃខែ) ប្រទេសដែលមានចំនូលមធ្យមកម្រិតខ្ពស់សំដៅលើប្រទេសណា ដែលប្រជាជនម្នាក់អាចរកប្រាក់ចំនូលជាមធ្យមបានចាប់ពី ៣៩៥៥ ដុល្លារអាមេរិក ទៅ ១២២៣៥ ដុល្លារអាមេរិច (ស្ថិតិឆ្នាំ២០១៨) ដូច្នេះក្នុងមួយខែ ប្រជាជនម្នាក់ ត្រូវមានប្រាក់ចំនូលជាមធ្យមយ៉ាងតិច ៣៣០ ដុល្លារអាមេរិក។ បើយោងតាមសេចក្តីសង្ខេបថវិកាឆ្នាំ ២០១៨ របស់ក្រសួងសេដ្ឋកិច្ច ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់នៅកម្ពុជា ត្រូវបានប៉ាន់ស្មានថានឹងមានចំនួន ១៥៦៨ ដុល្លារអាមេរិក ហើយកំណើនសេដ្ឋកិច្ចកម្ពុជារំពឹងថានឹងមានកំណើនថេរត្រឹម ៦.៩ ភាគរយ ដែលកំណើនសេដ្ឋកិច្ចនេះត្រូវបានទ្រទ្រង់ដោយវិស័យឧស្សាហកម្ម សេវាកម្ម និងកសិកម្ម។ មួយវិញទៀត វេទិការសេដ្ឋកិច្ចពិភពលោក ក៏បានព្យាករណ៍ផងដែរថា ការរស់នៅរបស់មនុស្សនៅក្នុងឆ្នាំ២០៣០ គឺភាគច្រើនពឹងផ្អែកលើបច្ចេកវិទ្យាទំនើប (វេទិការពិភពលោក, គ្មានថ្ងៃខែ)។ នេះសបង្ហាញឱ្យឃើញថា កម្ពុជានៅសល់ផ្លូវដ៏វែងឆ្ងាយទៀតក្នុងការបង្កើនល្បឿនអភិវឌ្ឍកម្រិតជីវភាពរបស់ប្រជាជនខ្លួនឱ្យបានទ្វេដង ធ្វើយ៉ាងណាឱ្យសមស្របទៅនឹងនិន្នាការវិវត្តនៃពិភពលោក ដើម្បីអាចនាំកម្ពុជាឈានទៅសម្រេចគោលបំណង នៅក្នុងកំឡុងពេល ១២ឆ្នាំខាងមុខទៀត។

បន្ទាប់ពីរៀបរាប់លើវិស័យអប់រំដ៏ស្មុគស្មាញខាងលើ ខ្ញុំសូមលើកយកចំណុចចំនួន៣មកបំពេញបន្ថែមដើម្បីជួយជាយោបល់ឱ្យកម្ពុជាអាចសម្រេចបានផលជាវិជ្ជមានក្នុងគោលដៅឆ្នាំ២០៣០ របស់ខ្លួន។ ចំនុចទាំង៣នេះរួមមាន កិច្ចសហប្រតិបត្តិការរវាងរដ្ឋ-ឯកជន ការវិនិយោគលើបច្ចេកវិទ្យា និងការទាញផលពីវប្បធម៌-សាសនា។

- ***កិច្ចសហប្រតិបត្តិការរវាងរដ្ឋ-ឯកជន (ទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្ត)***

យោងតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម បានបង្ហាញថាផ្នែកមួយនៃគោលដៅរយៈពេលវែង ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា តម្រូវឱ្យមានការដោះស្រាយលើបញ្ហាធនធានមនុស្ស ដោយត្រូវផ្តល់ការអភិវឌ្ឍចំនេះដឹងផ្នែកបច្ចេកទេស និងជំនាញ ដែលមានអាទិភាព ដើម្បីឱ្យឧស្សាហកម្មកម្ពុជាវិវត្តពីឧស្សាហកម្មអតិពលភាព ទៅជាឧស្សាហកម្មផ្អែកលើជំនាញនៅត្រឹមឆ្នាំ ២០២៥។ ដោយហេតុថានៅក្នុងសេដ្ឋកិច្ចទីផ្សារសេរី ការវិនិយោគភាគច្រើនបានមកពីស្ថាប័នឯកជន វាជាសញ្ញាណមួយដែលភាគីរដ្ឋ និងឯកជន គួរយកចិត្តទុកដាក់ចាប់ដៃគ្នា បង្កើត "កិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងឯកជន" ដើម្បីជួយបំពេញតម្រូវការឱ្យគ្នាទៅវិញទៅមក។ រដ្ឋាភិបាលអាចគិតគូរសហការជាមួយវិស័យឯកជន ធ្វើយ៉ាងណាកសាងធនធានមនុស្សឱ្យបានសមស្របគ្រប់គ្រាន់តាមតម្រូវការទីផ្សារការងារនៅក្នុងប្រទេស ក៏ដូចជានៅក្នុងតំបន់នាពេលអនាគត។ រីឯស្ថាប័នឯកជនគួរបន្ទាក់ទុនមួយចំនួនទទួលយកសិស្ស និស្សិត ឬកូនជាងដើម្បីបង្ហាត់ ឬបង្វឹកនៅកន្លែងធ្វើការផ្ទាល់ ដើម្បីឱ្យពួកគេទទួលបានចំណេះធ្វើនៅកន្លែងធ្វើការបន្ទាប់ពីទទួលបានចំណេះដឹងពីសាលា។ យុទ្ធសាស្ត្រនេះគឺចំណេញទាំងបីភាគី ពោលគឺភាគីខាងរដ្ឋចំណេញបានការពង្រឹងធនធានមនុស្ស ស្ថាប័នឯកជនចំណេញបានលើការទទួលបាន

បុគ្គលិកជំនាញពិតប្រាកដ (ជាធម្មតាការចំណាយលើសិស្សហាត់ការ ឬកូនជាង មិនស្រូវច្រើនដូចការចំណាយលើបុគ្គលិកជំនាញឡើង) រីឯសិស្ស និស្សិត ឬកូនជាង អាចទទួលបានការហ្វឹកហាត់ជំនាញអាជីពនៅកន្លែងការងារផ្ទាល់។ យុទ្ធសាស្ត្រនេះមិនមែនជាយុទ្ធសាស្ត្រថ្មីនោះទេ ដោយប្រទេសអភិវឌ្ឍមួយចំនួន បានប្រើប្រាស់ដើម្បីពង្រឹងការអភិវឌ្ឍធនធានមនុស្សជំនាញរបស់ខ្លួន ជាក់ស្តែងដូចជានៅប្រទេសកូរ៉េ ប្រទេសអាល្លឺម៉ង់ និងស្វីសជាដើម។

➢ ***ការវិនិយោគលើបច្ចេកវិទ្យា***

កម្ពុជាគួរត្រៀមបញ្ជៀតខ្លួន ចូលទៅក្នុងសាកលភាវូបនីយកម្មបច្ចេកវិទ្យា ព្រោះពិភពលោកកំពុងតែវិវត្តក្នុងសម័យកាលនៃបញ្ញាសម្បនិម្មិត្ត(AI) ក្នុងបដិវត្តន៍ឧស្សាហកម្ម៤.0 ទៅហើយ។ បញ្ញាសម្បនិម្មិត្ត បានចូលរួមចំណែក ក្នុងការផ្លាស់ប្តូរជីវភាពរស់នៅរបស់ប្រជាជនក្នុងពិភពលោក។ ឧទាហរណ៍ជាក់ស្តែង នៅកម្ពុជាបច្ចេកវិទ្យាបានផ្លាស់ប្តូរបណ្តើរៗនូវលទ្ធភាពធ្វើដំណើរ (Passapp, Grab) ឬការចាយវាយជាប្រព័ន្ធអេឡិចត្រូនិច (E-cash, Pi Pay…) ជាដើម។ ប្រសិនបើមិនបានដៅគោលដៅអប់រំឱ្យវិវត្តទៅតាមទំនោរនៃបច្ចេកវិទ្យានោះទេ កម្ពុជាអាចនឹងប្រឈមជាមួយបញ្ហាចម្បង ដោយបច្ចេកវិទ្យាថ្មី អាចនឹងមកជំនួសលើទីផ្សារការងារ របស់ប្រជាជន ដែលមិនអាចគ្រប់គ្រងបច្ចេកវិទ្យាទាំងនោះ។ ផ្ទុយទៅវិញ បើកម្ពុជាត្រៀមខ្លួនវិនិយោគបន្ថែមលើការបង្កើនចំណេះដឹង និងពង្រីកភាពច្នៃប្រឌិតរបស់កុមារ យុវជន ប្រជាជនឱ្យទាក់ទងនឹងបច្ចេកវិទ្យាទំនើប កម្ពុជានឹងឈានមួយជំហានទៅមុខ ថាមិនត្រូវក្លាយជាប្រទេសបច្ចេកវិទ្យាមានចំណូលមធ្យមកម្រិតខ្ពស់ក៏ថាបាន។

➢ ***ការទាញផលពីវប្បធម៌-សាសនា***

ប្រទេសកម្ពុជា ជាប្រទេសដែលមានអរិយធម៌ វប្បធម៌ និងសាសនាដ៏ចំណាស់មួយក្នុងតំបន់។ វប្បធម៌-សាសនាត្រូវបានផ្សាភ្ជាប់យ៉ាងជិតស្និតជាមួយសង្គមខ្មែរ។ យ៉ាងណាមិញ វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ "គឺអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យ និងបណ្តុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូប ឱ្យមានមោទនភាពជាតិ មានសីលធម៌ល្អ និងគុណភាពខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយម ចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន"។ ដូច្នេះក្រសួងអប់រំ ឬក្រសួងពាក់ព័ន្ធនានា គួរតែទាញយកផលប្រយោជន៍ពីវប្បធម៌-សាសនា ដើម្បីពង្រឹងដល់ប្រយោជន៍សង្គមជាតិ និងសម្រេចគោលដៅរបស់ខ្លួន។ បើនិយាយពីសាសនា រដ្ឋធម្មនុញ្ញបានចែងថាពុទ្ធសាសនា គឺជាសាសនារបស់រដ្ឋ ហើយវត្តអារាមពុទ្ធសាសនា មាននៅស្ទើរតែគ្រប់ឃុំស្រុក ទូទាំងប្រទេសកម្ពុជា។ បើយោងតាមសៀវភៅ អំពីប្រភពវប្បធម៌ខ្មែររបស់លោកមីសែស ត្រាណេ បានសរសេរថា "អារាមគឺជាកន្លែងអប់រំទាំងផ្លូវធម៌ ទាំងជំនាញបច្ចេកទេសផ្សេងៗ មុននឹងមានការចូលមកពីអាណានិគមនិយមបារាំង"។ មួយវិញទៀត មេដឹកនាំសាសនា គឺជាបុគ្គលដែលមានឥទ្ធិពលក្នុងសង្គម និងសហគមន៍ ដូច្នេះប្រសិនបើអាចមានកិច្ចសហការ ជាមួយមេដឹកនាំគ្រប់សាសនា មិនថាពុទ្ធសាសនា ឥស្លាម ឬគ្រិស្តសាសនានោះទេ សហការគ្នាផ្តួចផ្តើមបង្កើតមជ្ឈមណ្ឌលអប់រំ វិជ្ជាជីវៈក្រៅប្រព័ន្ធ សម្រាប់កម្មកររោងចក្រ ឬកសិករ ដើម្បីឱ្យពួកគាត់ទទួលបានវិជ្ជាជីវៈច្បាស់លាស់ណាមួយ ក្នុងការប្រកបរបរចិញ្ចឹមជីវិត។ ដូចដែលក្រសួងអប់រំកម្ពុជា លើកឡើងថា ការសិក្សាគឺពេញមួយជីវិត។

**ឯកសារពិគ្រោះ**


ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥។ (ឆ្នាំ២០១៥)

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ថវិកាសង្ខេប២០១៨, នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា។ (ឆ្នាំ២០១៨)

ក្រសួងអប់រំ យុវជន និងកីឡា, ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨។ (ឆ្នាំ២០១៤)

រដ្ឋាភិបាលកម្ពុជា, យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។ (ឆ្នាំ ២០១៥)

រដ្ឋាភិបាលកម្ពុជា, យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។ (ឆ្នាំ ២០១៨)
មេសែស ត្រាណេ, សៀវភៅ អំពីប្រភពវប្បធម៌ខ្មែរ។ (ឆ្នាំ ២០០៨)
វេទិការពិភពលោក, "ការព្យាករណ៍ទាំង៥ថាជីវិតនឹងទៅជាយ៉ាងណាក្នុងឆ្នាំ២០៣០"។ [https://www.weforum.org/agenda/2017/10/tech-life-predictions-for-2030/ ចូលមើលនៅថ្ងៃ១០ ខែធ្នូ ឆ្នាំ ២០១៨]
ធនាគារពិភពលោក, "ទិដ្ឋភាពទូទៅ"។ [http://www.worldbank.org/en/country/mic/overview ចូលមើលនៅថ្ងៃ៣០ ខែវិច្ឆិកា ឆ្នាំ២០១៨]

Cambodia Development Center
Cambodia Development Center (@cdcenter_kh)
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center
Building E, University of Puthisastra, #55, Street 180-184, Sangkat Boeung Raing, Khan Daun Penh
info@cd-center.com | (+855) 16 616 951